**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ៧-០៧-១១៦ ប្រ.ក

លិខិតចូល

ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ 20០៧

# ប្រកាស

## ស្តីពី

## ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញបទបញ្ជាលេខធ៧៩៥-០១បបជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហរបស់ធនាគារពាណិជ្ជ
- បានឃើញប្រកាសលេខធ៧-០០-៥០ប្រក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីដំណើរការគណនេយ្យកម្មសំរាប់ប្រតិបត្តិការរូបិយប័ណ្ណ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧

## ស ំ រ េ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង ដើម្បីបង្ការហានិភ័យនៃការប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ២.-**

សំរាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

- "ហានិភ័យនៃការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ខាងហិរញ្ញវត្ថុដែលកើតឡើងពីចលនាឡើងចុះនៃអត្រាប្តូរប្រាក់ ។
- "ហានិភ័យនៃការទូទាត់ការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយទូទាត់សងនូវរូបិយវត្ថុដែលខ្លួនបានលក់ តែអាចមិនទទួលមកវិញនូវរូបិយវត្ថុដែលខ្លួនបានទិញពីប្រតិបត្តិការប្តូរប្រាក់ ។
- "ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណណាមួយ" ជាសមតុល្យសុទ្ធនៃរាល់ទ្រព្យសកម្ម ទ្រព្យអកម្ម និងខ្ទង់ក្រៅតារាងតុល្យការនៃរូបិយប័ណ្ណនោះ ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណយិកគឺជាស្ថានភាពវែង ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណទាយីគឺជាស្ថានភាពខ្លី ។

**ប្រការ ៣.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពមួយ ដើម្បីកំណត់ វាស់វែង តាមដាន និងត្រួតពិនិត្យនូវទំហំនិងប្រភពហានិភ័យនៃការប្តូរប្រាក់ និងហានិភ័យនៃការទូទាត់ការប្តូរប្រាក់ក្នុងកំឡុងពេលនៃថ្ងៃជួញដូរនិងនៅពេលបិទបញ្ជីប្រចាំថ្ងៃ ។ លក្ខណៈនិងទំហំរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ ត្រូវស្របតាមទំហំនៃប្រតិបត្តិការប្តូរប្រាក់ និងស្ថានភាពប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ ។

**ប្រការ ៤.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាគ្រប់ពេល នូវស្ថានភាពចំហសុទ្ធជារូបិយប័ណ្ណណាមួយ ឬសរុបជារូបិយប័ណ្ណទាំងអស់ ទោះក្នុងស្ថានភាពវែងឬខ្លីក៏ដោយមិនឱ្យលើសពី ២០ភាគរយ នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះឡើយ ។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ប្រចាំខែ ទាំងហាដកូពី (Hard copy) និងសូហ្វកូពី (Soft copy) ស្តីពីស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ ឱ្យបានទៀងទាត់តាមគំរូក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវធានាផងដែរថា ស្ថានភាពរូបិយប័ណ្ណត្រូវបានរាយការណ៍ត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៧.-**

បទបញ្ជាលេខធ៧៩៥-០១បបជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហរបស់ធនាគារពាណិជ្ជ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ សីហា ឆ្នាំ២០០៧

ទេសាភិបាល

ជា-ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

## តារាង ឧបសម្ព័ន្ធ

## ការគណនាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ

## Net Open Position

ឈ្មោះធនាគារ..........៖
Bank's Name

កាលបរិច្ឆេទ..................................
As at............................

អត្រាប្តូរប្រាក់ ១ដុល្លារ (Exchange Rate 1USD) =
មូលនិធិផ្ទាល់សុទ្ធគិតជាលានរៀល (Bank's Net Worth)

គិតជាលានរៀល In Million KHR

| រូបិយប័ណ្ណ Currency | ធាតុផ្សេងៗបន្ទាប់ពីដកចេញសវិធានធន Elements after deduction of affected provision | | | | ស្ថានភាពរូបិយប័ណ្ណចំហសុទ្ធ Net Open Position | រូបិយប័ណ្ណចំហសុទ្ធ/ មូលនិធិផ្ទាល់សុទ្ធ (%) Net Open Position / Net Worth (%) | កំរិតកំណត់ (%) Limit (%) | ភាពលើស (១) Excess (1) |
|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | | | |
| | ទ្រព្យសកម្ម Assets | ទ្រព្យអកម្ម និងមូលធន Liabilities and Capital | រូបិយប័ណ្ណត្រូវទទួល Currencies Receivable | រូបិយប័ណ្ណត្រូវចំណាយ Currencies Payable | + (វែង) ឬ - (ខ្លី) +(Long) or -(Short) | | | |
| | + | - | ខ្ទង់ក្រៅតារាងតុល្យការ + Off Balance Sheet + | ខ្ទង់ក្រៅតារាងតុល្យការ - Off Balance Sheet - | (១ + ២ + ៣ + ៤) (1+2+3+4) | | | |
| USD | | | | | | | 20% | |
| KHR | | | | | | | 20% | |
| EUR | | | | | | | 20% | |
| SGD | | | | | | | 20% | |
| HKD | | | | | | | 20% | |
| THB | | | | | | | 20% | |
| JPY | | | | | | | 20% | |
| VND | | | | | | | 20% | |
| សរុប (Grand Total) | | | | | | | | |
| | (២) | (៣) | | | (៤) | | | |

(១) នៅពេលដែលមានភាពលើស ត្រូវស្ថាប័នធនាគារនិងហិរញ្ញវត្ថុត្រូវពន្យល់ជាលាយលក្ខណ៍អក្សរពីមូលហេតុនិងវិធានការកែសំរួល

(1) Where there is an excess, the bank shall submit a written explanation of the origin of each excess, and the measures taken to remedy the situation.

(២) ចំនួនសរុបទ្រព្យសកម្មក្នុងតារាងតុល្យការ

(2) Total equal to total assets on the balance sheet

(៣) ចំនួនសរុបទ្រព្យអកម្ម និងមូលធនក្នុងតារាងតុល្យការ

(3) Total equal to total liabilities on the balance sheet

(៤) ចំនួនសរុប ៖ សូន្យ

(4) Total = Zero

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

| នាយក Bank's Manager | អ្នកធ្វើតារាង Prepared By |
|---|---|

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.07 _ 134 Prokor.

Unofficial Translation

# PRAKAS
## on
## The monitoring of Banks' and Financial Institutions' Net Open Position in foreign currency

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0904/244 of September 7, 2004, on the appointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Regulation No B795-01 dated January 16, 1995, on the monitoring of Banks' and Financial Institutions' Open Foreign Exchange Positions:
- With reference to the Prakas No B7-00-50 dated February 17, 2000, on the accounting process for foreign currency transactions;
- Pursuant to the recommendation made by National Bank of Cambodia management during the August 15, 2007, meeting.

## DECIDES

### Article 1

This Prakas has the purpose of preventing Banks' and Financial Institutions' foreign exchange risks.

### Article 2

For the purposes of this Prakas, terms below are defined as follows:

- A "foreign exchange risk" results from the possibility of financial loss arising from adverse movements in foreign exchange rates.
- A "foreign exchange settlement risk" results from the possibility of loss that a financial institution (FI) pays the currency it sold but does not receive the currency it bought in a foreign exchange transaction.
- The "net open position in one foreign currency" is the net outstanding balance of all assets, liabilities, and off balance sheet items in that currency. The net open position in debit is defined as "long". The net open position in credit is defined as "short".

**Article 3**

Banks and Financial Institutions shall maintain an effective system of internal control to identify, measure, monitor and control the extent and source of their foreign exchange risk and foreign exchange settlement risk during the trading day and at the close of business. The nature and the size of the internal control system shall be adapted to the size of the Banks' and Financial Institutions' foreign exchange transactions and foreign exchange positions.

**Article 4**

Banks and Financial Institutions shall at all times maintain their net open position in foreign currencies in either any foreign currency or overall net open position in all foreign currencies, whether long or short, shall not exceed twenty percent (20%) of Banks' and Financial Institutions' net worth.

**Article 5**

Every month, Banks and Financial Institutions shall produce both hard copy and soft copy reports of their net open position in foreign currency to the National Bank of Cambodia according to the attached format. The internal control system shall also ensure that the foreign exchange positions are properly reported to the National Bank of Cambodia.

**Article 6**

Banks and Financial Institutions that are not compliant with this Prakas will be penalized according to Article 52 of the Law on Banking and Financial Institutions.

**Article 7**

The Regulation No B795-01 dated January 16, 1995, on the monitoring of Banks' and Financial Institutions' Open Foreign Exchange Positions and all provisions contrary to those of this Prakas are hereby repealed.

**Article 8**

The General Director, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banks and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 9**

This Prakas shall take effect from this signing date.

Phnom Penh, August 27, 2007

**The Governor**

**Signed and Sealed**

cc:
- All members of the Board of Directors
- The parties concerned as stated in Article 8
- File
- CM "for info"
- Administration Department of CM "for publication in the National Gazette"